

# ម៉ោងអាន ដំណើររឿងព្រះគម្ពីរ

ដោយ ន័រមែន ហីល
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅប្រទេសហ្គាណា ។*

លោក អូតូ បាននិយាយថា « ដល់ម៉ោងអំណានហើយ » ។

នីម៉ាអី អង្គុយត្រង់ខ្លួន ។ ម៉ោងអំណានគឺសប្បាយណាស់ !

ជារៀងរាល់ថ្ងៃនៅសាលារៀន គ្រូបង្រៀនរបស់ពួកគេអានសៀវភៅផ្សេងៗឲ្យសិស្សស្ដាប់ ។ ពេលខ្លះគាត់អានអំពីសត្វ ។ ពេលខ្លះគាត់អានអំពីមនុស្សនៅប្រទេសផ្សេងៗ ។ ហើយពេលខ្លះគាត់បានសួរសិស្សក្នុងថ្នាក់ថាតើពួកគេមានសៀវភៅណាដែលពួកគេចង់ឲ្យគាត់អានឬទេ ។

« តើមាននរណាម្នាក់មានសៀវភៅដែលចង់ឲ្យខ្ញុំអាននៅថ្ងៃនេះដែរឬទេ ? » លោក អូតូ បានសួរ ។

នីម៉ាអី បានលើកដៃឡើង ។ « ខ្ញុំមាន ! គាត់លូកដៃចូលកាតាបរបស់គាត់ ហើយទាញសៀវភៅដែលគាត់ចូលចិត្តមក ។ នេះជាដំណើររឿងនៃព្រះគម្ពីរមរមន !

គាត់បានយកសៀវភៅនេះដើម្បីមកអានក្រោយចេញពីរៀន នៅពេលគាត់រង់ចាំម្ដាយគាត់មកទទួលគាត់ ។ ការមើលឃើញរូបភាពបានជួយគាត់ឲ្យយល់អំពីដំណើររឿងក្នុងព្រះគម្ពីរ ។

លោក អូតូ ញញឹមពេលឃើញសៀវភៅធំនោះ ។ « យើងនឹងមិនមានពេលអានវាទាំងអស់នោះទេ ។ តើមានផ្នែកណាមួយដែលប្អូនចង់ឲ្យខ្ញុំអានដែរឬទេ ?

នីម៉ាអី បានឆ្លើយថា « បាទមាន » ។ គាត់បានបើករកទំព័រ រហូតឃើញដំណើររឿងដែលគាត់ចូលចិត្ត ។ « សូមលោកគ្រូអានដំណើររឿងនេះបានទេ ? ដំណើររឿងនេះគឺជា ‹ សុបិនរបស់លីហៃ › » ។

« តើដំណើររឿងនេះអំពីអ្វីទៅ ? » លោក អូតូ បានសួរ ។

« ដំណើររឿងនេះគឺអំពីព្យាការីម្នាក់ដែលមានការនិមិត្តមួយ ។ លោកបានឃើញដើមឈើដ៏ស្រស់ស្អាតមួយមានផ្លែដ៏ឆ្ងាញ់ » ។ នីម៉ាអី ចង្អុលទៅរូបភាពដើមឈើនោះ ។ « លោកចង់ឲ្យគ្រួសាររបស់លោកហូបផ្លែឈើនោះជាមួយលោក ។ សូមលោកគ្រូអានបានទេ ? » នីម៉ាអី បានហុចសៀវភៅទៅលោកគ្រូរបស់គាត់ ។

« ពិតជាបាន » លោក អូតូ បាននិយាយ បន្ទាប់មកគាត់ចាប់ផ្ដើមអានឮៗ ។ គាត់បានអានអំពីផ្លូវតូច និងចង្អៀតដែលនាំទៅរកដើមឈើនោះ ។ គាត់បានអានអំពីដំបងដែក ។ ហើយគាត់បានអានអំពីការគោរពតាមបទបញ្ញត្តិទាំងឡាយ ។

មិត្តភក្តិរបស់ នីម៉ាអី មានឈ្មោះថា ស៊ីឡូម បានលើកដៃរបស់គាត់ឡើង ។ គាត់បានសួរ នីម៉ាអី ថា « តើវាជាដើមឈើបែបណាទៅ ? »

នីម៉ាអី បាននិយាយថា « ខ្ញុំមិនដឹងទេ ។ « ប៉ុន្តែផ្លែឈើនោះគឺឆ្ងាញ់ណាស់ ។ ផ្លែឈើនោះប្រាកដជាឆ្ងាញ់ជាងផ្លែស្វាយទៅទៀត ! » បន្ទាប់មក នីម៉ាអី បានឈប់គិតមួយភ្លែត ។ « នៅឯព្រះវិហារ ខ្ញុំបានរៀនថា ផ្លែឈើនេះតំណាងឲ្យសេចក្ដីស្រឡាញ់របស់ព្រះ ។ ដូច្នេះ វាសមហេតុផលដែលថា វាឆ្ងាញ់ហើយពិសេសនោះ ! » ។

ពេលរៀនចប់ នីម៉ាអី បានអង្គុយនៅខាងក្រៅដើម្បីរង់ចាំម្ដាយរបស់គាត់ ។ គាត់បានទាញសៀវភៅដំណើររឿងព្រះគម្ពីរមរមនចេញដើម្បីអានបន្ថែមទៀត ។

ស៊ីឡូម បាននិយាយថា « សៀវភៅនោះឡូយណាស់ » ។ គាត់អង្គុយក្បែរ នីម៉ាអី ។ « តើខ្ញុំអាចអានដំណើររឿងមួយទៀតជាមួយឯងបានទេ ? »

« បាទបាន ! » នីម៉ាអី បានបើកទៅរកដំណើររឿងមួយទៀត ។ ពួកគេបានអានអំពីអ័ប៊ីណាដៃ និងស្ដេចណូអេ ។

មិត្តរួមថ្នាក់របស់ពួកគេកាន់តែច្រើនទៀតបានមកស្ដាប់ ។ នៅពេលពួកគេមានសំណួរ នីម៉ាអី បានឆ្លើយសំណួរទាំងនោះ ។ គាត់ថែមទាំងបានសួរសំណួរទៅពួកគេ ដើម្បីសួរពួកគេអំពីដំណើររឿងដែលពួកគេអាន !

មិនយូរប៉ុន្មាន នីម៉ាអី បានឃើញម្ដាយគាត់ដើរទៅរកពួកគេ ។ គាត់បាននិយាយទៅកាន់ក្មេងៗផ្សេងទៀតថា « អរគុណដែលបានអានជាមួយខ្ញុំ » ។ គាត់បិទសៀវភៅ ហើយញញឹម ។ គាត់សប្បាយចិត្តដែលមិត្តភក្តិរបស់គាត់ចូលចិត្តដំណើររឿងដែលគាត់ចូលចិត្តយ៉ាងខ្លាំង ដូចគាត់ដែរ ។



*« តើមាននរណាម្នាក់មានសៀវភៅដែលចង់ឲ្យខ្ញុំអាននៅថ្ងៃនេះដែរឬទេ ? » លោក អូតូ បានសួរ ។*

តើដំណើររឿងព្រះគម្ពីរដែលអ្នកចូលចិត្តនោះគឺជារឿងអ្វី ?